# ដំណាំស្ពៃក្តោប

## I. ស្ថានភាពទូទៅ



ស្ពៃក្តោបជាដំណាំមួយប្រភេទ ដែល មានប្រភពពីកំណើតមកពីទ្វីបអឺរ៉ុប ។ ជាយូរយារកន្លងមកដំណាំនេះត្រូវបាន គេដាំនៅក្នុងតំបន់អឺរ៉ុបប៉ែកខាងកើតនិងតំបន់មួយចំនួនក្នុង ទ្វីបអាហ្វ្រិក ។ ក្រោយមកដោយវិទ្យាសាស្ត្របង្កាត់ ពូជជឿនលឿនគេបានបង្កាត់ពូជតំរូវ ទៅតាមតំបន់ដាំដុះដំណាំប្រភេទនេះស្ថិតនៅក្នុងគ្រួសារ Gruciferaeក្នុងអំបូរBrassica Oleracea ។ ស្ពៃក្តោបជាទូទៅចែកចេញជា ៣ ប្រភេទទៅតាមពណ៌នៃស្លឹក:

-ពូជស្លឹកពណ៌ស្វាយ

-ពូជស្លឹកពណ៌ស

-ពូជស្លឹកពណ៌ក្រហម

ការនិយមដាំនៅប្រទេសកម្ពុជា វៀតណាម ឡាវ ថៃ គឺពូជឈ្មោះ KK Gross ផលិតដោយក្រុមហ៊ុន Takiiseed Company ។ នៅពេលថ្មីៗនេះនៅប្រទេសភីលីពិន។



គេនិយមដាំពូជឈ្មោះ Rareball ដែលផលិត ដោយក្រុមហ៊ុន Kaneco Seed Company នៃប្រទេសជប៉ុន ។ គ្រាប់ពូជមានភាពល្អិតៗ ទំងន់ ១ក្រាមមាន ចំនួន ២០០-៣០០ គ្រាប់ ដើម្បីដាំ១ហាត គេប្រើគ្រាប់ពូជចំនួន៣៥០-៤០០ ក្រាម ។

## II. បច្ចេកទេសដាំដុះ

### ១- ការជ្រើសរើសរដូវ

ការជ្រើសរើសរដូវមានសារៈសំខាន់នៅក្នុងការដាំដុះដំណាំ ។ រដូវទាក់ទងនឹង សីតុណ្ហភាព ភ្លៀង សំណើម បរិយាកាស ជំងឺ និង សត្វល្អិត។ ដំណាំស្ពៃក្តោបគេច្រើន តែដាំនៅរដូវត្រជាក់ ។ នៅប្រទេសកម្ពុជាយើងគេអនុវត្តន៍ពីខែតុលា ដល់ខែកុម្ភៈ ចន្លោះពេលនេះគឺសីតុណ្ហភាពត្រជាក់ ពន្លឺថ្ងៃ និង ចំណាំងរបស់ពន្លឺសមស្រប សត្វល្អិត និង ជំងឺមិនមានការរាតត្បាតខ្លាំង។ ចំពោះពូជឈ្មោះ KK Cross មកពីជប៉ុន រដូវនេះសមស្របល្អជាងពូជឯទៀតៗ។

### ២-ការជ្រើសរើស និងរៀបចំដី

ដំណាំស្ពៃក្តោបជាប្រភេទដំណាំមួយត្រូវការដុះលូតលាស់លើប្រភេទដីធូរស្រទាប់ ដាំដុះជ្រៅសំបូរទៅដោយជាតិមមោកព្រមទាំងសំបូរទៅដោយ សារធាតុចិញ្ចឹមផ្សេងៗទៀត ។ ដំណាំនេះគេរាប់បញ្ចូលទៅក្នុងក្រុមមិនធុនទ្រាំនឹងដីអាស៊ីដគេរៀបចំដីដោយប្រើត្រាក់ទ័រគោយន្ត ឬដោយនង្គ័លគោ មុននឹងភ្ជួរគេរាស់ទុកដីឱ្យស្ងួតស្រស់ទឹក ហើយប្រមូលយកស្មៅ ឬកាកសំណល់ចេញពីដីឱ្យស្អាត ទើបគេភ្ជួរលើកដំបូងក្រោយ។

ពីភ្ជួរហើយគេត្រូវហាលដីនោះរយៈពេល ២ទៅ៣ថ្ងៃ រាស់បំបែកដីឱ្យល្អិត ទើបភ្ជួរ ប្រែដី លើកទី២ ក្រោយពីភ្ជួរហើយ ត្រូវហាលដីនោះ ឱ្យស្ងួតល្អ ដើម្បីឱ្យស្មៅ ឬ សត្វល្អិតចង្រៃងាប់ ប៉ុន្តែចំពោះដី ដែលកង្វះជាតិកំបោរ គេបាចកំបោរចំនួន ២៥០ ទៅ៣៥០ គ.ក្រ/ហ.ត ហើយរាស់លប់ទៅក្នុងដី។ គេភ្ជួរនឹងរាស់ចំនួន ២-៣ លើកឱ្យ បានជ្រៅ និងឱ្យល្អិតធានាឱ្យមានបន្ទុកខ្យល់គ្រប់គ្រាន់ និងឱ្យទឹកជ្រាបបានល្អរក្សាសំណើមដីបានយូរ។ ជាទូទៅការរៀបចំដីសំរាប់ដំណាំបន្លែ គឺដីស្ងួត និងមានប្រភពគ្រប់គ្រាន់ដើម្បីស្រោចស្រព ។







៣-ការបណ្តុះកូន

ដើម្បីធានាឱ្យកូនស្ពៃក្តោបដុះលូតលាស់ល្អគ្មានជំងឺ និងសត្វល្អិតបំផ្លាញ គេគួរតែជ្រើសរើសកន្លែង សំរាប់សាបកូនដែលមានលក្ខខណ្ឌដូចតទៅ ។ ដីមាន ជីជាតិ នៅក្បែរប្រភពទឹកឃ្លាតឆ្ងាយពីចំការ ស្ពៃឯទៀត វាលស្រឡះមានពន្លឺគ្រប់គ្រាន់ ។ គេត្រូវភ្ជួរ ឬរៀបដីនោះឱ្យផុសល្អរើសយកស្មៅចេញហាល ដីឱ្យស្ងួត វាយបំបែក ដីឱ្យម៉ត់ល្អ ហើយបាចកំបោរសចំនួន ២៥០ក្រាម លើផ្ទៃដី ២០ម$^{២}$ ក្រោយមក លើករងឱ្យបានខ្ពស់គឺទទឹង ១ម បណ្តោយ ១០ម កំពស់ពី ១៥-២០ សម ត្រូវយកជី ១៥.១៥.១៥ ចំនួន ១៥០ ក្រាម ទៅបាចពីលើ ហើយរាស់លប់ដីនោះឱ្យ។

កប់ទៅក្នុងដី (ហាមប្រើជីលាមកសត្វ មិនទាន់ពុក ) ក្រោយមកទៀតយកថ្នាំប្រភេទ Furadan ២០ ក្រាម និងប្រភេទថ្នាំផ្សិតឈ្មោះ Mancozeb ឬ Orthocide ចំនួន ១៥ ក្រាម ទៅបាចលើថ្នាលនោះ ទើបគេសាបគ្រាប់ស្ពៃទៅក្នុងថ្នាលដោយប្រើទំងន់ គ្រាប់ចំនួន ៧-១០ក្រាមលើផ្ទៃដី១០ម$^{២}$ដើម្បីដាំលើផ្ទៃដី ១ ហ.ត គេត្រូវប្រើគ្រាប់ពូជចំនួន ៣០០-៣៥០ក្រាម ។ ក្រោយពីសាបហើយត្រូវយកកំទេចចំបើងស្ងួតកាត់ ឱ្យខ្លីៗបាចពីលើឱ្យក្រាស់ហើយស្រោចឱ្យជោគ ហើយគ្របសំណាញ់ពណ៌ខៀវក្រឡាញឹកឱ្យជិត ការពារកុំឱ្យពពួកសត្វល្អិតចូលបំផ្លាញដើម្បីឱ្យកូនស្ពៃដុះល្អគេចាប់ផ្តើមដក ស្មៅនិងដករំលស់កូនស្ពៃចេញឱ្យរង្វើលក្រោយពីសាបរយៈ ពេល ៨-១០ថ្ងៃ ហើយ ស្រោចបំប៉នជី Urea ៤៦% ដោយប្រើកំរិត ១ស្លាបព្រាបាយ លាយទឹក ២០លីត្រ ឱ្យជោគហើយស្រោចទឹកធម្មតាតាមក្រោយ។ ក្រោយមកទៀតកូនស្ពៃអាយុ ១៨-២០ ថ្ងៃ គេស្រោចជីបំប៉នដោយប្រើប្រភេទ ៤៦% ដដែលកំរិត១ ស្លាបព្រាយ Urea (១០-១៥ក្រាម) លាយទឹក ១៥-២០លីត្រ ស្រោចឱ្យជោគ និងស្រោចទឹកធម្មតា តាមក្រោយ ។ អនុវត្តតាមវិធីនេះរយៈពេល ២៥-២៨ ថ្ងៃ គេអាចដកកូនស្ពៃយកទៅដាំ ប៉ុន្តែមុននឹងយកទៅរយៈពេល ២ថ្ងៃ គេផ្អាកការស្រោចទឹកឱ្យកូនស្ពៃធន់ទ្រាំ និងការកង្វះទឹក និងកំដៅថ្ងៃដល់ពេលរៀបដកត្រូវស្រោចទឹកឱ្យជោគទើបគេដក កូនយកទៅដាំ គឺវាមានសន្លឹក៣-៤ កំពស់ ៨-១០សម។ ចំពោះវិធីផ្សាំកូនវិញគេ ដកកូនស្ពៃមានអាយុ ១៤-១៦ថ្ងៃ មានសន្លឹក២ គឺគេផ្សាំក្នុងកន្ទោង ឬស្បោង ដោយក្នុងនោះមានលាយជីផេះអង្កាម និងជីធម្មជាតិផុសល្អក្រោយពីផ្សាំក្នុងកន្ទោង ហើយស្រោចទឹកជោគ និងគ្របពេលថ្ងៃ រយៈពេល ២ថ្ងៃ ទើបលែង គ្រប គឺបើកចំហ



ទាំងយប់ ទាំងថ្ងៃលើកលែងតែពេលភ្លៀង ទើបគ្របគំរប ការពារពីលើ ។ ក្រោយពី ផ្សាំរយៈពេល ១០-១២ថ្ងៃ អាចដាំបាន ។

៤- ការដាំដុះស្ពៃក្តោប

ដើម្បីការដាំដុះដំណាំស្ពៃក្តោបបានល្អ ដំបូងត្រូវលើករងជាមុនសិន។ គេលើក រងឱ្យបានកំពស់ ពី ១៥-២០ស.ម ទទឹង ១០០ស.ម បណ្តោយ ១០-១៥ម ក្នុងករណីដីមានជំរាល គេគួរតែលើករងទទឹងជំរាលរបស់ដីក្រោយមកទៀតគេរាស់ដោយរនាស់ដៃយកស្មៅចេញ និងពង្រាបរងស្មើល្អ ទើបគេកាប់រណ្តៅនៅលើរងជា២ជួរ ចន្លោះ ។



ជួរ ៧០សម ន្លោះរណ្តៅគឺ ៥០-៦០សម បន្ទាប់មកយកជីគីមីប្រភេទ ១៥.១៥.១៥ ឬ (១៨ . ៤៦ . ០ )ចំនួន ២០០គក្រ ជីលាមកសត្វ ឬកំប៉ុស្ដិ៍ចំនួន ១៥-២០តោន និង រោយថ្នាំប្រភេទ Furadan ចំនួន ១០ គ.ក្រ ក្នុងផ្ទៃដី ១ហ.ត ហើយជ្រំលាយបញ្ចូលគ្នាទើប យកកូនមកដាំ ។ កូនស្ពៃក្ដោបមុននឹងយកទៅដាំត្រូវស្រោចទឹកឱ្យជោគជាមុន ១គុម្ព ១ដើម គេដាំនៅពេលថ្ងៃរសៀល ដាំហើយភ្លាមត្រូវស្រោចទឹកឱ្យជោគ។ គេបន្តការស្រោចទឹកក្នុង១ថ្ងៃ ៣ លើក ព្រឹក ថ្ងៃត្រង់ និងល្ងាចរយៈពេល ២ថ្ងៃ ។

**៥-ការស្រោចស្រព**





ដំណាំអំប៉ូវស្ពៃត្រូវការទឹកជាប្រចាំប៉ុន្តែវាមិនត្រូវការសំណើមដីខ្ពស់ពេកនោះទេ ជាមធ្យមចន្លោះពី ៨០-៨៥% មធ្យមប្រចាំថ្ងៃ ។ គេស្រោចទឹកបានច្រើនវិធី គឺស្រោចដោយប៉ោត ព្រឹក និងល្ងាច លើផ្ទៃដី ១៥ម$^{២}$ ក្នុង១ ថ្ងៃ ជាមធ្យមពី ៧០-៨០ លីត្រ ។ ចំពោះការស្រោចដោយឧបករណ៍ម៉ាស៊ីនទំនើប ១ ថ្ងៃ គេបាញ់ម្តងជា ពិសេសនៅពេលល្ងាចជាការល្អ ។ ចំពោះការស្រោចដោយបញ្ចូលផ្ទាល់គេធ្វើឡើងលើប្រភេទដីរាបស្មើ និង ដំណាក់កាលស្ពៃក្ដោបរួចហើយ។ ដំណាំនេះត្រូវការទឹកខ្លាំងក្នុងដំណាក់កាលក្រោយដាំ៤៥-៥០ថ្ងៃ ។

**៦-ការជ្រំជ្រួយដី**

